រាជរដ្ឋាភិបាលកម្ពុជា
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation-Religion-King

ថ្ងៃសុក្រ ១១រោច ខែអស្សុជ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៦

សេចក្តីប្រកាសព័ត៌មាន

គម្រោងវិនិយោគចំនួន ៣៧ ក្នុងទំហំទុនវិនិយោគសរុបប្រមាណ ២៤៦លានដុល្លារអាម៉េរិក ត្រូវបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា

កាលពីខែតុលា ឆ្នាំ២០២៦ កន្លងទៅនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក.) និងអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត (អ.គ.វ.រ.ខ.) បានចុះបញ្ជីគម្រោងវិនិយោគសរុបចំនួន ៣៧គម្រោង ក្នុងទំហំទុនវិនិយោគសរុបប្រមាណ ២៤៦លានដុល្លារអាម៉េរិក និងអាចបង្កើតឱកាសការងារជូនប្រជាពលរដ្ឋបានប្រមាណ ១៩៣ន់កន្លែង។ ក្នុងចំណោមគម្រោងវិនិយោគខាងលើ គម្រោងដែលត្រូវបានចុះបញ្ជីដោយ ក.អ.ក. មានចំនួន២៤គម្រោង ក្នុងទំហំទុនវិនិយោគសរុបប្រមាណ ២០៥លានដុល្លារអាម៉េរិក និងអាចបង្កើតឱកាសការងារជូនប្រជាពលរដ្ឋបានប្រមាណ ១១៣ន់កន្លែង។ ដោយឡែក គម្រោងវិនិយោគដែលត្រូវបានចុះបញ្ជីដោយ អ.គ.វ.រ.ខ. មានចំនួន១៣គម្រោង ក្នុងទំហំទុនវិនិយោគប្រមាណ ៤១លានដុល្លារអាម៉េរិក និងអាចបង្កើតការងារជូនប្រជាពលរដ្ឋបានប្រមាណ ៨៣ន់កន្លែង។ ជាការកត់សម្គាល់ ក្នុងរយៈពេល ១០ខែនៃឆ្នាំ២០២៦ វិស័យឧស្សាហកម្មនៅតែជាវិស័យស្នូលក្នុងការទាក់ទាញវិនិយោគ ខណៈការវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស និងគម្រោងវិនិយោគក្នុងវិស័យកសិកម្ម ទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធ នៅតែបន្តរួមចំណែកដល់ការធ្វើពិពិធកម្មសកម្មភាពសេដ្ឋកិច្ច និងការបង្កើតការងារនៅកម្ពុជា។

គម្រោងវិនិយោគដែលមានភាពលេចធ្លោប្រចាំខែតុលា រួមមាន៖

ក.ក្រៅតំបន់សេដ្ឋកិច្ចពិសេស

កសិកម្ម និង កសិ-ឧស្សាហកម្ម

គម្រោងវិនិយោគបង្កើតរោងចក្រផលិតចំណីសត្វចិញ្ចឹម

- **ទីតាំង៖** ស្រុកព្រៃនប់ ខេត្តព្រះសីហនុ
- **ទំហំទុនវិនិយោគប្រមាណ៖** ២០លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ៨០៩កន្លែង។

ហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗ

គម្រោងវិនិយោគអភិវឌ្ឍន៍ស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព១០០មេហ្គាវ៉ាត់

- **ទីតាំង៖** ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង
- **ទំហំទុនវិនិយោគប្រមាណ៖** ៤២លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ៩១កន្លែង។

ខ.ក្នុងតំបន់សេដ្ឋកិច្ចពិសេស

ឧស្សាហកម្ម

គម្រោងវិនិយោគបង្កើតរោងចក្រផលិតផលិតផលវាយនភណ្ឌ

- **ទីតាំង៖** តំបន់សេដ្ឋកិច្ចពិសេស **កំពង់ស្ពឺ ជីន ធីង អ៊ុនធើណោសិនណល**
- **ទំហំទុនវិនិយោគប្រមាណ៖** ២២លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ៨១កន្លែង។

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

គម្រោងវិនិយោគក្នុង ខែតុលា ឆ្នាំ២០២៦

ដែលត្រូវបានអនុម័តនៅក្នុងព្រះរាជាណាចក្រកម្ពុជា



គម្រោងវិនិយោគ
៣៧
គម្រោង



ទុនវិនិយោគ
២៤៦
លានដុល្លារអាមេរិក



បង្កើតការងារ
~១៩៣ន់
កន្លែង

ទុនវិនិយោគតាមវិស័យ (គិតជាដុល្លារអាមេរិក)



ប្រភពទុនវិនិយោគឈានមុខ



របាយគម្រោងវិនិយោគនៅតាមបណ្តារាជធានី-ខេត្ត

